# ភទ្ទសាលជាតក



*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធ**ញាតត្ថចរិយា** បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **កា ត្វំ សុទ្ធេហិ វត្ថេហិ** ដូច្នេះជាដើម ។*

*(រឿងរ៉ាវបច្ចុប្បន្ន អ្នកសិក្សាគប្បីជ្រាបតាមន័យ ដែលពោលមកហើយ ក្នុងធម្មបទ បុប្ផវគ្គ វិដូដភវត្ថុនោះចុះ) ។*

*ភិក្ខុទាំងឡាយអង្គុយក្នុងធម្មសភាពោលគុណកថារបស់ព្រះដ៏មានព្រះភាគថា ម្នាលអាវុសោ ព្រះសាស្តាសម្តែងនូវខ្លួន ធ្វើព្រះបាទវិដូដភៈឲ្យវិលត្រឡប់ ញុាំងពពួកញាតិឲ្យរួចចាកមរណភ័យ ព្រះសាស្តាជាអ្នកប្រព្រឹត្តប្រយោជន៍ដល់ញាតិយ៉ាងនេះ ។ ព្រះសាស្តាយាងមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយរឿងអ្វី ? កាលពួកភិក្ខុទូលថា រឿងនេះ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនកាលឥឡូវនេះទេ ដែលតថាគតប្រព្រឹត្តនូវប្រយោជន៍ដល់ពពួកញាតិនោះ សូម្បីកាលមុន ក៏តថាគតបានប្រព្រឹត្តដែរ ដូច្នេះហើយទ្រង់នាំយកអតីតនិទានមកសម្តែងថា*

ក្នុងអតីតកាល ព្រះរាជាព្រះនាមព្រហ្មទត្តមិនធ្វើ**ទសរាជធម៌**ឲ្យកម្រើក សោយរាជសម្បត្តិប្រកបដោយធម៌ ក្នុងនគរពារាណសី ។ ថ្ងៃមួយ ទ្រង់គិតថា លើផ្ទៃជម្ពូទ្វីបនេះ មានព្រះរាជាទាំងឡាយសោយរាជសម្បត្តិលើប្រាសាទសសរច្រើន ព្រោះហេតុនោះ ធម្មតាប្រាសាទសសរច្រើនមិនជាអស្ចារ្យទេ ប្រសិនបើយើងឲ្យគេធ្វើប្រាសាទមានសសរតែមួយ យើងនឹងជាអគ្គរាជាលើព្រះរាជាទាំងអស់យ៉ាងនេះ ។ ព្រះបាទព្រហ្មទត្តនោះឲ្យគេហៅជាងឈើមក រួចទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរកសាងប្រាសាទសសរមួយដែលដល់ព្រមដោយភាពស្រស់ស្អាតដល់យើង ។ ពួកជាងឈើទទួលថា ល្អ ថារួចចូលទៅកាន់ព្រៃ ឃើញដើមឈើជាច្រើន មានដើមត្រង់ ហើយធំ ដែលសមគួរនឹងធ្វើប្រាសាទសសរមួយបាន ពួកជាងឈើគិតថា ដើមឈើទាំងឡាយនេះមាន ប៉ុន្តែផ្លូវមិនស្មើ មិនអាចនឹងដាក់ចុះបាន យើងនឹងទូលព្រះរាជាសិន គិតហើយ ក៏បានធ្វើយ៉ាងនោះ ។

ព្រះរាជាត្រាស់ថា អ្នកទាំងឡាយចូរដាក់ចុះដោយឧបាយណាមួយយ៉ាងសន្សឹមៗចុះ ។ ជាងឈើពោលថា បពិត្រព្រះសម្មតិទេព មិនអាចធ្វើដោយឧបាយណាមួយទេ ។ ព្រះរាជាត្រាស់ថា បើយ៉ាងនោះ អ្នកទាំងឡាយចូររកមើលដើមឈើក្នុងឧទ្យានរបស់យើងចុះ ។

ពួកជាងឈើទៅកាន់ឧទ្យាន ឃើញសាលព្រឹក្សមួយដើមដែលជាមង្គល ជាដើមដុះល្អ មានដើមត្រង់ ដែលអ្នកស្រុកនិងនិគមតែងបូជា និងជាទីទទួលពលិកម្មអំពីរាជត្រកូល ឃើញហើយ ពួកគេទៅកាន់សំណាក់ព្រះរាជា ប្រាប់សេចក្តីនោះដល់ព្រះអង្គ ។

ព្រះរាជាត្រាស់ថា ធម្មតាដើមឈើក្នុងឧទ្យានតែងបដិព័ទ្ធនឹងយើង ចូរអ្នកទាំងឡាយទៅកាត់ដើមឈើចុះ ។ ជាងឈើទទួលថា ល្អ ថាហើយជាអ្នកមានដៃកាន់គ្រឿងក្រអូបនិងកម្រងផ្កាទៅកាន់ឧទ្យាន ថ្វាយកម្មដែលបុគ្គលធ្វើដោយម្រាម ៥ គឺបុគ្គលចឹម លាប ចុចដោយវត្ថុមានក្លិននៅនឹងដើមឈើ រុំព័ទ្ធដោយសរសៃសូត្រ ចងហោជាងផ្កា អុជប្រទីប ធ្វើពលិកម្ម រួចស្រែកប្រកាសថា ចាប់អំពីថ្ងៃនេះទៅ ក្នុងថ្ងៃទី ៧ ពួកយើងមកកាត់ដើមឈើនេះ

ព្រះរាជាទ្រង់អនុញ្ញាតឲ្យកាត់, សូមទេវតាទាំងឡាយដែលកើតនៅនឹងដើមឈើនេះ ចូរទៅកាន់ទីដទៃចុះ ទោសកំហុសកុំមានដល់ពួកយើង ។

លំដាប់នោះ ទេវបុត្រដែលកើតនៅលើដើមសាលៈ ស្តាប់ពាក្យនោះហើយ គិតថា "មិនមានសង្ស័យឡើយ ជាងឈើទាំងនេះនឹងកាត់ដើមឈើនេះ វិមានរបស់យើងនឹងវិនាស ចំណែកជីវិតរបស់យើងនៅទីបំផុតវិមាន, វិមានទាំងឡាយជាច្រើននិងជីវិតរបស់ទេវតាដែលជាញាតិរបស់យើង ដែលកើតលើដើមសាលៈតូចៗ ដែលឋិតនៅឡោមព័ទ្ធដើមឈើនេះ នឹងវិនាស, សេចក្តីវិនាសវិមានមិនបៀតបៀនខ្លួនយើង ក៏ដូចមិនបៀតបៀនពួកញាតិ ព្រោះហេតុនោះ យើងគួរឲ្យជីវិតដល់ពួកញាតិទាំងនោះ" គិតរួច ក្នុងពេលពាក់កណ្តាលរាត្រី ទេវបុត្រនោះប្រដាប់តាក់តែងដោយគ្រឿងអលង្ការទាំងពួង ចូលទៅកាន់បន្ទប់ដ៏មានសិរីរបស់ព្រះរាជា ធ្វើបន្ទប់ទាំងអស់ឲ្យមានពន្លឺតែមួយ ឈរយំស្រែកលើក្បាលដំណេក ។

ព្រះរាជាឃើញទេវបុត្រនោះ មានសេចក្តីភ័យខ្លាច កាលនឹងចរចាជាមួយទេវបុត្រ ទើបត្រាស់គាថាទី ១ ថា

**កោ តុំ សុទ្ធេហិ វត្ថេហិ, អឃេ វេហាយសំ ឋិតោ;**
**កេន ត្យាស្សូនិ វត្តន្តិ, កុតោ តំ ភយមាគតំ។**

***អ្នកជាអ្វី ដែលមានសំពត់ទាំងឡាយដ៏ស្អាត បានឋិតនៅលើអាកាសវេហាស៍ ទឹកភ្នែកទាំងឡាយរបស់អ្នកហូរចេញ តើដោយហេតុអ្វី ភ័យមកចំពោះអ្នក ព្រោះអ្វី ។***

លំដាប់នោះ ទេវរាជពោល ២ គាថាថា

**តវេវ ទេវ វិជិតេ, ភទ្ទសាលោតិ មំ វិទូ;**
**សដ្ឋិ វស្សសហស្សានិ, តិដ្ឋតោ បូជិតស្ស មេ។**

*បពិត្រព្រះសម្មតិទេព ជនទាំងឡាយ ក្នុងដែនរបស់ព្រះអង្គ ស្គាល់ច្បាស់នូវខ្ញុំថា ជាភទ្ទសាលព្រឹក កាលខ្ញុំឋិតនៅ ( ក្នុងឧទ្យាននេះ ) អស់ ៦ ម៉ឺនឆ្នាំ ជនទាំងឡាយ បានបូជាហើយ ។*

ការយន្តា នគរានិ, អគារេ ច ទិសម្បតិ;
វិវិធេ ចាបិ បាសាទេ, ន មំ តេ អច្ចមញ្ញិសុំ;
យថេវ មំ តេ បូជេសុំ, តថេវ ត្វម្បិ បូជយ។

*បពិត្រព្រះអង្គជាម្ចាស់ទិស ( ព្រះរាជាទាំងឡាយពីដើមក្នុងនគរនេះ ) កាលឲ្យគេសាងទីក្រុងទាំងឡាយផង ដំណាក់ទាំងឡាយផង ប្រាសាទផ្សេង ៗ ផង មិនដែលបៀតបៀនខ្ញុំឡើយ ព្រះរាជាទាំងនោះ បូជាខ្ញុំ យ៉ាងណា សូមព្រះអង្គបូជាខ្ញុំ យ៉ាងនោះដែរ ។*

*បន្ទាប់មក ព្រះរាជាត្រាស់ ២ គាថាថា*

តំ ឥវាហំ ន បស្សាមិ, ថូលំ កាយេន តេ ទុមំ;
អារោហបរិណាហេន, អភិរូបោសិ ជាតិយា។

*ខ្ញុំមិនធ្លាប់ឃើញអ្នក ជាដើមឈើធំ ដោយកាយរបស់អ្នកទេ អ្នកជាឈើមានទ្រង់ទ្រាយដ៏ល្អ ដោយកម្ពស់ និងទំហំ និងកំណើត ។*

បាសាទំ ការយិស្សាមិ, ឯកត្ថម្ភំ មនោរមំ;
តត្ថ តំ ឧបនេស្សាមិ, ចិរំ តេ យក្ខ ជីវិតំ។

*ម្នាលយក្ខ ខ្ញុំនឹងឲ្យគេធ្វើប្រាសាទ មានសសរតែមួយ ជាទីរីករាយនៃចិត្ត ខ្ញុំនឹងនាំយកអ្នកចូលទៅក្នុងប្រាសាទនោះ ជីវិតរបស់អ្នក ( នឹងមាន ) អស់កាលយូរ ។*

*ទេវរាជស្តាប់ពាក្យនោះហើយ ពោល ២ គាថាថា*

ឯវំ ចិត្តំ ឧទបាទិ, សរីរេន វិនាភាវេ;
បុថុសោ មំ វិកន្តិត្វា, ខណ្ឌសោ អវកន្តថ។

*( បើ) ព្រះទ័យ ( របស់ទ្រង់) កើតឡើងយ៉ាងនេះ សេចក្ដីព្រាត់ប្រាស ( ចាកភទ្ទសាលព្រឹក្ស) ជាសរីរៈ ( របស់ខ្ញុំនឹងមានប្រាកដ) ( កាលបើយ៉ាងនេះ) សូមព្រះអង្គ កាត់ខ្ញុំ ជាច្រើនកំណាត់ កាត់ជាកំណាត់តូចធំចុះ ។*

អគ្គេ ច ឆេត្វា មជ្ឈេ ច, បច្ឆា មូលម្ហិ ឆិន្ទថ;
ឯវំ មេ ឆិជ្ជមានស្ស, ន ទុក្ខំ មរណំ សិយា។

*តែសូមព្រះអង្គកាត់ត្រង់ចុង និងកណ្ដាល ( មុន) រួចកាត់ត្រង់គល់ ក្នុងកាលជាខាងក្រោយ កាលបើខ្ញុំត្រូវព្រះអង្គកាត់យ៉ាងនេះ សេចក្ដីស្លាប់ មិនគប្បីជាទុក្ខទេ ។*

*ព្រះរាជាត្រាស់ ២ គាថាថា*

ហត្ថបាទំ យថា ឆិន្ទេ, កណ្ណនាសញ្ច ជីវតោ;
តតោ បច្ឆា សិរោ ឆិន្ទេ, តំ ទុក្ខំ មរណំ សិយា។

*ដូចយ៉ាងបុគ្គលកាត់ដៃ និងជើងផង ត្រចៀក និងច្រមុះផង ឲ្យស្លាប់បាត់ជីវិត តពីនោះគេកាត់នូវក្បាលក្នុងកាលខាងក្រោយ សេចក្ដីស្លាប់នោះ ក៏ជាទុក្ខដែរ ។*

សុខំ នុ ខណ្ឌសោ ឆិន្នំ, ភទ្ទសាល វនប្បតិ;
កិំហេតុ កិំ ឧបាទាយ, ខណ្ឌសោ ឆិន្ទមិច្ឆសិ។

*ម្នាលភទ្ទសាលព្រឹក្ស ជាម្ចាស់នៃព្រៃ ការកាត់ជាកំណាត់ស្រួល ឬ ព្រោះហេតុអ្វី ប្រារព្ធហេតុអ្វី បានជាអ្នកចង់ឲ្យគេកាត់ជាកំណាត់ ។*

*ពេលនោះ កទ្ទសាលទេវតាកាលនឹងប្រាប់ព្រះរាជា ទើបពោល ២ គាថាថា*

យញ្ញា ហេតុមុចានាយ, ហេតុំ ជម្ពូបសំហិតំ;
ខណ្ឌសោ ឆិន្ទមិច្ឆាមិ, មហារាជ សុណោហិ មេ។

*បពិត្រមហារាជ ខ្ញុំចង់ឲ្យគេកាត់ជាកំណាត់ ព្រោះអាស្រ័យហេតុ ដែលប្រកបដោយហេតុណា សូមព្រះអង្គទ្រង់ស្តាប់នូវហេតុនោះ របស់ខ្ញុំចុះ ។*

ញាតី មេ សុខសំវទ្ធា, មម បស្សេ និវាតជា;
តេបិហំ ឧបហឹសេយ្យំ, បរេសំ អសុខោចិតំ។

*ពួកឈើជាញាតិរបស់ខ្ញុំ ចម្រើនដុះដាលដោយសេចក្តីសុខ កើតក្នុងទីមិនមានខ្យល់ នៅជិតខាងខ្ញុំ (កាលបើទ្រង់កាប់រំលំខ្ញុំ) ខ្ញុំមុខជានឹងរលំ សង្កត់ពួកឈើជាញាតិនោះ សេចក្តីទុក្ខនឹងកើតមាន ដល់ពួកឈើជាញាតិដទៃទៀត ។*

*ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់មានចិត្តរីករាយថា ទេវបុត្រនេះជាធម្មិកណាស់តើ ! មិនប្រាថ្នាសេចក្តីវិនាសវិមានដល់ពួកញាតិ ដែលកើតពីការវិនាសវិមានរបស់ខ្លួន, ប្រព្រឹត្តនូវអត្ថចរិយាដល់ពួកញាតិ យើងនឹងឲ្យអភ័យដល់គេ ដូច្នេះហើយ ទ្រង់ត្រាស់គាថាចុងក្រោយថា*

ចេតេយ្យរូបំ ចេតេសិ, កទ្ទសាល វនប្បតិ;
ហិតកាមោសិ ញាតីនំ, អភយំ សម្ម ទម្មិ តេ។

*ម្នាលកទ្ទសាលព្រឹក្ស ជាម្ចាស់នៃព្រៃ អ្នកគិតនូវហេតុ ដែលមានសភាពគួរគិត អ្នកជាឈើប្រាថ្នានូវប្រយោជន៍ ដល់ពួកឈើជាញាតិ ម្នាលសម្លាញ់ ខ្ញុំឲ្យអភ័យដល់អ្នក ។*

*ទេវរាជសម្ដែងធម៌ដល់ព្រះរាជាហើយក៏ទៅ ។ ព្រះរាជាតាំងនៅក្នុងឱវាទទេវតា ធ្វើបុណ្យមានឲ្យទានជាដើម បានទៅកើតក្នុងទេវលោក ។*

*ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតក៏បានប្រព្រឹត្តនូវញាតត្ថចរិយាដែរ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា*

តទា រាជា អានន្ទោ អហោសិ *ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទ*

តរុណសាលេសុ និព្វត្តទេវតា ពុទ្ធបរិសា *ទេវតាដែលកើតនៅនឹងដើមសាលៈតូចៗ បានមកជាពុទ្ធបរិស័ទ*

ភទ្ទសាលទេវរាជា បន អហមេវ អហោសិំ *ចំណែកភទ្ទសាលទេវរាជ គឺតថាគតនេះឯង ។*

*ភទ្ទសាលជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសកនិបាត បិដកលេខ ៥៩ ទំព័រ ២៣៩)*

*ថ្ងៃច័ន្ទ ២ រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ១៣៨១ ម.ស. ១៩៤១ ព.ស. ២៥៦៣*

*ត្រូវនឹងថ្ងៃទី ២០ ខែឧសភា គ.ស. ២០១៩*

*ដោយសដវថ*